*សម្រាប់ការចេញផ្សាយបន្ទាន់*

# កម្ពុជា ៖ ការកាត់ទោសសម រង្ស៊ីបំផ្លាញជំនឿប្រជាធិបតេយ្យ

## *ការកាត់ទោសមេដឹកនាំបក្សប្រឆាំងបង្ហាញពីការត្រួតត្រាកបដោយចរិតនយោបាយលើប្រព័ន្ធតុលាការ*

*(ញូវយ៉ក ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០) - អង្គការឃ្លាំមើលសិទ្ធិមនុស្សបាននិយាយនៅថ្ងៃនេះថា ការកាត់ទោសចុងក្រោយលើលោក សម រង្ស៊ី មេដឹកនាំបក្សប្រឆាំងនៅកម្ពុជា លើបទចោទប្រកាន់មានបែបផែនជានយោបាយ បង្ហាញឲ្យឃើញយ៉ាងច្បាស់ថា រដ្ឋាភិបាលរបស់នាយករដ្ឋមន្ត្រីហ៊ុនសែនលែងចាប់អារម្មណ៍នឹងជំនឿប្រជាធិបតេយ្យតទៅទៀតហើយ។ លោក សម រង្ស៊ី ត្រូវបានគេកាត់ទោសដាក់គុកចំនួន ១០ ឆ្នាំ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ លើបទចោទប្រកាន់ស្ដីពីការផ្សាយព័ត៌មានមិនពិត និងការក្លែងបន្លំផែនទី។*

*អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានជំរុញឲ្យប្រធានាធិបតី បារ៉ាក់ អូបាម៉ា ប្រាប់ទៅហ៊ុនសែន នៅពេលដែលពួកគេជួបគ្នានៅថ្ងៃនេះថា ឧប្បត្តិហេតុនេះនឹងគំរាមកំហែងដល់ជំនួយ និងទំនាក់ទំនងអន្តរជាតិជាមួយប្រទេសកម្ពុជា ជាពិសេសប្រសិនបើរដ្ឋាភិបាលខកខានចាត់វិធានការបន្ទាន់ ដើម្បីលប់ចោលវិធានការទាំងឡាយដែលបំផ្លាញសេរីភាពសម្ដែងមតិ សេរីភាព ជួបប្រជុំ និងសមាគម។ លោក អូបាម៉ា មានកាលវិភាគជួបប្រជុំជាមួយមេដឹកនាំសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) នៅក្នុងទីក្រុងញូវយ៉ក ក្នុងកំឡុងពេលដែលមេដឹកនាំទាំងនេះចូលរួមក្នុងមហាសន្និបាតរបស់អង្គការសហប្រជាជាតិ។*

*លោកស្រី សូភី រីឆាតសុន នាយកស្ដីទីប្រចាំទ្វីបអាស៊ីរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានប្រសាសន៍ថា "លោកប្រធានាធិបតី អូបាម៉ា និងមេដឹកនាំពិភពលោកដទៃទៀត ចាំបាច់ត្រូវឲ្យលោក ហ៊ុន សែន និងរដ្ឋាភិបាលរបស់លោកដឹងថា ការជិះសេះលែងដៃនោះគឺចប់ហើយ។ កម្ពុជាមិនអាច*

*កាត់ទោស មេដឹកនាំបក្សប្រឆាំងឲ្យជាប់គុក ១០ឆ្នាំ  ចំពោះការសម្តែងមតិដោយសន្តិវិធី ដោយគ្មានបង្ករឲ្យមានផលវិបាកធ្ងន់ធ្ងរនោះបានឡើយ។"*

*តុលាការបានកាត់ទោសលោក រង្ស៊ី មេដឹកនាំបក្សប្រឆាំងតាំងពីឆ្នាំ១៩៩៨មក ចំពោះការផ្សព្វផ្សាយផែនទីមួយដែលអះអាងបង្ហាញថា ព្រំដែន    ប្រទេសកម្ពុជាជាមួយប្រទេសវៀតណាមត្រូវបានគេរំកិល។ ការជំនុំជម្រះទោស ត្រូវបានប្រព្រឹត្តទៅដោយបិទបាំងពីសាធារណជន ថ្វីបើសាលក្រមត្រូវបានអានដោយចៅក្រម កែ សាខន ថា "អំពើប្រព្រឹត្តដោយជនល្មើស បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយសរបស់រដ្ឋាភិបាល។" លោក   រង្ស៊ី ដែលបាននិរទេសខ្លួនឯងទៅក្រៅប្រទេស អស់រយៈពេលពេញមួយឆ្នាំនៅឆ្នាំនេះ ប្រឈមនឹងការចាប់ដាក់គុក ប្រសិនបើគាត់វិលត្រឡប់មកកម្ពុជាវិញ។*

*ករណីនេះគឺជាផ្នែកមួយនៃយុទ្ធនាការឥតរាថយ  និងយូរលង់ប្រឆាំងនឹង  លោក  រង្ស៊ី។ កាលពីថ្ងៃទី២៧ ខែមករា តុលាការខេត្រស្វាយរៀង បានកាត់ទោសលោក  រង្ស៊ី និងអ្នកភូមិពីរនាក់ឈ្មោះ មាស ស្រី និង    ព្រហ្ម ជា    ពីបទញុះញង់ឲ្យមានការរើសអើងពូជសាសន៍ និងបំផ្លិចបំផ្លាញបង្គោលព្រំដែននៅតាមព្រំដែនកម្ពុជា-វៀតណាម។ ការកាត់ទោសនោះ ផ្អែកលើឧប្បត្តិហេតុក្នុងខែតុលា ឆ្នាំ២០០៩ ខណៈពេលដែលលោក រង្ស៊ី ជួយអ្នកភូមិក្នុងខេត្រស្វាយរៀងដកបង្គោលកំណត់ព្រំដែនសីមា ដែលពួកគេបានអះអាងថា បានបោះចូលក្នុងទឹកដីរបស់ប្រទេសកម្ពុជា។*

*លោកស្រី  រីធាតសុន  មានប្រសាសន៍ថា "ការកាត់ទោស  លោក  រង្ស៊ី បាននាំយកយុទ្ធនាការរបស់លោក  ហ៊ុនសែន  ក្នុងការធ្វើទុក្ខបុកម្នេញអ្នករិះគន់ ទៅកាន់ ស្ថានភាពដ៏ជ្រុលហួសហេតុបំផុតមួយ និងបង្ហាញយ៉ាងច្បាស់ពីការត្រួតត្រារបស់រដ្ឋាភិបាលលើប្រព័ន្ធតុលាការ។ ម៉្យាងទៀត អាជ្ញាធរកម្ពុជា ជាទម្លាប់តែងតែរកពេល  ដើម្បីប្រើប្រាស់ប៉ូលីស  និងតុលាការ  អោយវាយប្រហារអ្នករិះគន់ ប៉ុន្តែ  មិនដែលបានចាប់ខ្លួន ឬកាត់ ទោសជនទាំងឡាយណាដែលបានវាយប្រហារទៅលើអ្នករិះគន់ដូចគ្នាទាំងនេះទេ ដែលការវាយប្រហារជាញឹកញយរហូតដល់ស្លាប់ក៏មាន។"*

*អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានជំរុញឲ្យសហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ជប៉ុន និងម្ចាស់ជំនួយសំខាន់ៗដទៃទៀត ឲ្យចាត់វិធានការផ្អែកការទូតឲ្យខ្លាំងក្លា ឆ្លើយតបចំពោះការកាត់ទោសប្រឆាំងនឹង*

*លោក រង្ស៊ី រួមទាំងការអំពាវនាវដល់ឯកអគ្គរាជទូតរបស់ខ្លួន អោយបង្ហាញពីប្រតិកម្មរបស់ពួកគេ។ ម្ចាស់ជំនួយបានបរិច្ចាគថវិកាប្រមាណជា៥០ ភាគរយនៃថវិការបស់រដ្ឋាភិបាលកម្ពុជា។*

*ចាប់តាំងពីពេលដែលលោក រង្ស៊ី បង្កើតគណបក្សនយោបាយរបស់លោកក្នុងឆ្នាំ១៩៩៥មក លោក រង្ស៊ី បានទទួលរងនូវអំពើប៉ុនប៉ងធ្វើឃាត អំពើគំរាមកំហែង បំភិតបំភ័យ ករណីព្រហ្មទណ្ឌ និង ករណីរដ្ឋប្បវេណីជាច្រើន។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ ការវាយប្រហារដោយគ្រាប់បែកដៃ មកលើការជួបប្រជុំខាងនយោបាយដែលគាត់កំពុងតែថ្លែងទៅកាន់នោះ បានសម្លាប់មនុស្សចំនួន ១៦នាក់ និងធ្វើឲ្យរបួស ១៥០នាក់។ ជីវិតរបស់លោករង្ស៊ី ត្រូវបានជួយសង្គ្រោះ ខណៈពេលដែល កម្លាំង គ្រាប់ផ្ទុះពេញទំហឹងបានជះមកលើអង្គរក្សមួយរូប ក្នុងចំណោមអង្គរក្សទាំងឡាយរបស់ លោក។*

*ការិយាល័យសហព័ន្ធស៊ើបអង្កេតរបស់សហរដ្ឋអាមេរិក ដែលបានធ្វើការស៊ើបអង្កេតពីព្រោះតែ ប្រជាពលរដ្ឋអាមេរិកាំងមួយរូប ទទួលរងរបួសក្នុងការវាយប្រហារនោះ បានរកឃើញថាកងអង្គរក្ស របស់លោកហ៊ុនសែន បានជាប់ពាក់ព័ន្ធនឹងការវាយប្រហារដោយគ្រាប់បែកនោះ ប៉ុន្តែរដ្ឋាភិបាល កម្ពុជាបានខកខានស៊ើបអង្កេត ឬនាំខ្លួនជនដែលទទួលខុសត្រូវទៅកាត់ទោស។*

*មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ បាន ដាក់ពាក្យបណ្តឹងដែលមានការជំរុញខាងនយោបាយ ម្តងហើយម្តង ទៀត ប្រឆាំងនឹងលោក រង្ស៊ី ក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ អភ័យឯកសិទ្ធិតំណាងរាស្ត្ររបស់លោក ត្រូវបានគេដកហូតក្នុងខែកុម្ភះ ឆ្នាំ២០០៩ បន្ទាប់ពី លោក ហ៊ុនសែន ដាក់ពាក្យ បណ្តឹងពីបទបរិហា កេរ្តិ៍ប្រឆាំងនឹងរូបលោកចំពោះការចោទលោកហ៊ុនសែនពីអំពើពុករលួយ។ អភ័យឯកសិទ្ធិរបស់ លោក រង្ស៊ី ត្រូវបានគេផ្តល់មកវិញបន្ទាប់ពីគណបក្សរបស់លោកបង់ប្រាក់ពិន័យចំនួន ២៥០០ ដុល្លារអាមេរិក។ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ អភ័យឯកសិទ្ធិរបស់លោកត្រូវបានគេដកហូតម្តងទៀត ទាក់ទងនឹងករណីបង្គោលព្រំដែន។*

*ការប៉ុនប៉ងមួយផ្សេងទៀតដើម្បីដាក់គុកលោក រង្ស៊ី គឺកើតឡើង កាលពីក្នុងខែធ្នូ ឆ្នាំ២០០៥ ខណៈ ពេលដែលគាត់ត្រូវបានគេកាត់ទោសដាក់គុក ១៨ខែ ពីបទបរិហារកេរ្តិ៍ដែលមានលក្ខណៈ*

នយោបាយ យ៉ាងច្បាស់ក្រឡែត។ លោក រង្ស៊ី បានចេញក្រៅប្រទេសនៅពេលនោះ។ ក្រោមការគាបសង្កត់ជាអន្តរជាតិ ហ៊ុន សែន បានយល់ព្រមចំពោះការផ្តល់នូវការលើកលែងទោស ក្នុងខែកុម្ភៈ ឆ្នាំ២០០៦។

លោកស្រី រីតាតសុន មានប្រសាសន៍ថា "អស់ រយៈពេលដ៏យូរហួសហេតុពេកហើយ ដែលម្ចាស់ជំនួយធ្វើជាមិនដឹងមិនលឺ អំពីការរារាំង បន្ទុចបង្អាក់ កាន់តែអាក្រក់ទៅៗ ចំពោះសិទ្ធិ និងប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។ ប្រសិនបើពួកគេ នៅបន្តមិនបញ្ចេញប្រតិកម្មទេ នោះ ពួកគេនឹងភ្ញាក់ខ្លួនឡើងនៅថ្ងៃណាមួយ ហើយនិងដឹងថា កម្ពុជាប្រាកដជាប្រហាក់ប្រហែលនឹងប្រទេសភូមា។ វាជាពេលវេលាសម្រាប់អ្នកការទូតក្រោកឈរឡើង និងធ្វើការប្រមាណមើល។"